# សំណើរបស់មេធាវីអន្តរជាតិនួនជាសុំឱ្យសហចៅក្រម ស៊ើបអង្កេតជាតិលាឈប់ពីដំណែង

**លីម ជ័យទត្ត**

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ ក្រុមមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា បានផ្ញើរលិខិតមួយច្បាប់តាមរយៈសារអេឡិចត្រូនិច ជូនសហចៅក្រមស៊ើបអង្កេតជាតិ លោក យូ ប៊ុនឡេង ដោយស្នើសុំឲ្យលោកចៅក្រមលាឈប់ពីមុខដំណែង។ ការស្នើសុំនេះ ធ្វើឡើងក្រោយពេលអង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចមួយ ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ រ៉ូប៊ឺត ហាមីល (Robert Hamil) នៅក្នុងសំណុំរឿង០០៣[1] នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបន្ទាប់ពីមានអត្ថបទចុះផ្សាយជាបន្តបន្ទាប់នៅតាមបណ្តាសារព័ត៌មានក្នុងស្រុក ទាក់ទងនឹងយោបល់របស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ។

នៅក្នុងយោបល់ដាច់ដោយឡែករបស់ខ្លួន លោកចៅក្រម រ៉ូវ៉ាន់ដូនណើង Rowan Downing និងចៅក្រម កាត់ទីនកា ឡាអ៊ីស Katinka Lahuis យល់ឃើញថា សហចៅក្រមស៊ើបអង្កេតទាំងពីររូប គឺលោកចៅក្រម យូ ប៊ុនឡេង និងចៅក្រម ស៊ីកហ្វ្រេដ ប៊្លុង Siegfried Blunk បានប្រព្រឹត្តភាពមិនប្រក្រតីធ្ងន់ធ្ងរខាងនីតិវិធី រួមមាន ការចុះកាលបរិច្ឆេទថយក្រោយលើឯកសារ ការកែប្រែនូវឯកសារ និងការខកខានមិនបានជូនដំណឹងឲ្យបានត្រឹមត្រូវដល់មេធាវីការពារក្តីក្នុងសំណុំរឿង០០៣។

ក្រុមមេធាវីអន្តរជាតិរបស់ជនជាប់ចោទនួនជា បានទាមទារឲ្យលោកចៅក្រម យូ ប៊ុនឡេង បង្ហាញជាបន្ទាន់រាល់ឯកសារនៅក្នុងសំណុំរឿង០០២ ដែលមានការចុះកាលបរិច្ឆេទថយក្រោយ កែប្រែជាសម្ងាត់លើឯកសារ ឬក្លែងក្លាយ ឬឯកសារទាំងឡាយដែលបានលាក់បាំងពីមេធាវីការពារជនជាប់ចោទ។ ការស្នើសុំឲ្យមានការបង្ហាញដូច្នេះ បានធ្វើឡើងបន្ទាប់ពីការលាតត្រដាងរបស់ចៅក្រមអន្តរជាតិនៅអង្គបុរេជំនុំជម្រះ ស្តីអំពីការប្រព្រឹត្តភាពមិនប្រក្រតីធ្ងន់ធ្ងរខាងនីតិវិធីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបណ្តាលឲ្យមានមន្ទិលសង្ស័យពីសំណាក់ក្រុម

[1] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោករ៉ូប៊ឺតហាមីល (Robert Hamil) ចុះថ្ងៃទី២៨ ខែតុលាឆ្នាំ២០១១ ឯកសារលេខD11/2/4/4 ។

មេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា ពីសុចរិតភាពរបស់លោកចៅក្រមរូបនេះ ក្នុងការស៊ើបអង្កេត និងគាត់តែងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ។[២] ក្រុមមេធាវីអន្តរជាតិរបស់ នួន ជា បានចាត់ទុកទង្វើរបស់សហចៅក្រមស៊ើបអង្កេត លោក យូ ប៊ុនឡេង និងលោក ស៊ីកហ្វ្រេដ ប៊្លុង Siegfried Blunk ទាក់ទងនឹងការកែប្រែ "ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក រូប៊ីត ហាមីល" ថាជាការប្រព្រឹត្តបទឧក្រិដ្ឋដោយយោងទៅលើមាត្រា៦២៩ នៃក្រមព្រហ្មទណ្ឌ[៣] ទាក់ទងនឹងការក្លែងបន្លំឯកសារសាធារណៈ ។ នៅក្នុងយោបល់ដាច់ដោយឡែករបស់ខ្លួន លោកចៅក្រម ដូនណីង Downing និងចៅក្រម ឡាអ៊ីស Lahuis បានលើកឡើងពាក់ព័ន្ធនឹងដីកាកែប្រែថា

> ដីកាដែលត្រូវបានជំទាស់ បានដកចេញពីក្នុងសំណុំរឿង ហើយជំនួសដោយដីកាកែប្រែ ។ ទោះបីជាដីកាកែប្រែទំនងជាបានធ្វើឡើងនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១១ ក៏ដោយ ដីកាកែប្រែនេះបែរជាដាក់កាលបរិច្ឆេទត្រឡប់ថយក្រោយវិញ ពោលគឺថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ។ យើងសង្កេតឃើញទៀតថា សេចក្តីណែនាំស្តីពីការដាក់ឯកសារ ក៏បានដាក់កាលបរិច្ឆេទត្រឡប់ថយក្រោយទៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ដូចគ្នា ទោះបីជាដីកាកែប្រែត្រូវបានកត់សម្គាល់យ៉ាងជាក់លាក់ ដោយមន្ត្រីទទួលបន្ទុកសំណុំរឿងថា ដីកានេះពិតជាបានដាក់នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០១១ ក៏ដោយ ។[៤]
>
> ការកែប្រែទាំងនេះមានគោលបំណងដោយមិនសមហេតុផល ដើម្បីជួសជុលវិការៈសំខាន់ៗនានានៅក្នុងដីកាដែលត្រូវបានជំទាស់ ដែលបានបដិសេធចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤ ក្រោយពីការពិចារណាលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលបានដាក់នៅក្នុងរឿងក្តីនេះ ពោលគឺមិនបានសម្រេចលើពាក្យសុំដែលបានដាក់នៅក្នុងសំណុំរឿង០០៣ឡើយ ។[៥]

---

[២] លិខិតរបស់ក្រុមមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ ជូនសហចៅក្រមស៊ើបអង្កេតជាតិ លោក យូ ប៊ុនឡេង កម្មវត្ថុៈ "សំណើសុំបញ្ជីសម្ភារៈដែលជិតដាមក្នុងសំណុំរឿង០០២ និងស្នើឲ្យលាឈប់ពីការងារ" ។

[៣] មាត្រា៦២៩ៈ ការក្លែងបន្លំប្រព្រឹត្តនៅក្នុងលិខិតយថាភូត ឬការក្លែងបន្លំប្រព្រឹត្តនៅក្នុងឯកសារដែលចេញដោយរាជការសាធារណៈ ដើម្បីធ្វើការកត់សំគាល់សិទ្ធិ អត្តសញ្ញាណ ឬឋានៈ ឬដើម្បីយល់ព្រមដល់ការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ ទៅ១០ឆ្នាំ ។

[៤] ការពិចារណារបស់អង្គបុរេជំនុំជម្រះ យោបល់របស់ចៅក្រម Downing និង Lahuis នៅកថាខណ្ឌទី១៣ ទំព័រ១៤ (ភាសាខ្មែរ) ។

[៥] ដូចខាងលើ ។ កថាខណ្ឌទី១៤ ទំព័រ១៦ ។

ដោយយោងទៅលើការលើកឡើងអំពីកំហុសដែលប្រព្រឹត្តឡើងដោយសហចៅក្រមស៊ើបអង្កេត ក្រុមមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា បានស្នើសុំឲ្យមានការស៊ើបឲ្យមានការស៊ើបអង្កេតខាងវិន័យទៅលើលោកចៅក្រម យូ ប៊ុនឡេង ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ការស្នើសុំឲ្យលាឈប់ពីដំណែងដែលសំដៅតែចំពោះលោកចៅក្រម យូ ប៊ុនឡេង ម្នាក់ គឺដោយសារតែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លោក ស៊ីកហ្វ្រេដ ប៊្លុង Siegfried Blunk បានដាក់ពាក្យស្នើសុំលាលែងពីដំណែងកាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១១ ទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិរួចទៅហើយ ។

ការស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតលាឈប់ពីមុខដំណែង របស់ក្រុមមេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា ជាការធ្វើឡើងបន្ថែមលើអ្វីដែលអង្គការក្រៅរដ្ឋាភិបាលផ្សេងៗបានធ្វើ ។ នៅក្នុងរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) ដែលចេញផ្សាយនៅថ្ងៃទី៣ ខែតុលា ឆ្នាំ ២០១១ បានធ្វើការរិះគន់ទៅលើសហចៅក្រមស៊ើប អង្កេត និងអំពាវនាវឲ្យសហចៅក្រមស៊ើបអង្កេតទាំងពីររូបលាឈប់ពីមុខដំណែងដែរ ដោយលើកឡើងថាសហចៅក្រមស៊ើបអង្កេតទាំងពីររូបមិនបានធ្វើការដោយអព្យាក្រឹតក្នុងសំណុំរឿង០០៣ និង ០០៤ ។[៦] មួយសប្តាហ៍ក្រោយការអំពាវនាវនេះ សហចៅក្រមអន្តរជាតិ លោក ស៊ីកហ្វ្រេដ ប៊្លុង Siegfried Blunk បានដាក់ពាក្យស្នើសុំលាលែងពីដំណែង ដោយបានលើកឡើងពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលចូលទៅក្នុងដំណើរការសំណុំរឿង០០៣ និង០០៤ ដែលជាហេតុផលនៃការលាលែងរបស់លោក ។[៧]

នៅក្នុងលិខិតដែលសរសេរទៅលោកចៅក្រម យូ ប៊ុនឡេង ក្រុមមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា បានលើកឡើងថា ការបន្តវត្តមានរបស់លោកចៅក្រមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងធ្វើឲ្យបាត់បង់នូវជំនឿបន្ថែមទៀតមកលើសាលាក្តីមួយនេះ ។ លើសពីនេះ ក្រុមមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា ចូលរួមជាមួយនឹងអង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) អំពាវនាវឲ្យលោកចៅក្រមជាតិ យូ ប៊ុនឡេង លាឈប់ពីមុខដំណែង ។

---

[៦] របាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស(Human Rights Watch) ដែលចេញផ្សាយនៅថ្ងៃទី៣ ខែតុលា២០១១ មានចំណងជើងថា«កម្ពុជាៈ ចៅក្រមស៊ើបអង្កេតរបស់សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមគួរលាឈប់ពី ដំណែង» ។

[៧] សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលធ្វើឡើងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១១ ។